CAMBODIAN TRADE UNIONS FEDERATION

BWTUC

Building and Wood Workers Trade Union Federation of Cambodia

CENTRAL

CICA

CHRAC

CAMBODIAN HUMAN RIGHTS ACTION COALITION

CCAWDU

COALITION OF CAMBODIAN APPAREL WORKERS DEMOCRATIC UNION

UCL

UNION COALITION FOR LABOUR

C.Y.N

INTERNATIONAL LABOR RIGHTS FORUM

ILRF

www.laborrights.org

INTUFE

IDEA

LIPS

Lembaga Informasi Perburuhan SEDANE

BWI

www.bwint.org

CFSWF

C.T.W.U.F

CAMBODIAN TOURISM WORKERS UNION FEDERATION

LICADHO

fidh

AMNESTY INTERNATIONAL

Maquila Solidarity Network

SOLIDARITY

usas

ANFREL

Asian Network for Free Elections

HUMAN RIGHTS WATCH

ADHOC

GLOBAL LABOR JUSTICE

FUFI

COMFREL

LION INDONESIA

LOCAL INITIATIVE FOR OSH NETWORK

Asia FLOOR WAGE

CIVIL RIGHTS DEFENDERS

Clean Clothes Campaign

International Office

SOLIDAR SUISSE

FIGHTING FOR GLOBAL FAIRNESS

Cambodian Center for Human Rights

CIVICUS

FORUM-ASIA

Labor Rights Supported Union of Khmer Employees of Naga World

L.R.S.U

Index: ASA 23/1604/2019

**គោរពជូន សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**
អាសយដ្ឋាន: វិមានសន្តិភាព , 38 មហាវិថី សហពន្ធ័រុស្សី (110),
រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា
ខែ ធ្នូ ឆ្នាំ ២០១៩

**ច្បាប់ស្តីពី សហជីព និង ករណីចោទប្រកាន់ប្រឆាំងនឹងថ្នាក់ដឹកនាំសហជីព**

**សម្តេចអគ្គមហាសេនាបតីតេជោ ជាទីគោរព**

យើងខ្ញុំទាំងអស់គ្នាតំណាងឲ្យអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិមានមានការព្រួយបារម្ភជាខ្លាំងចំពោះការស្នើធ្វើវិសោធនកម្មច្បាប់ស្តីពីសហជីពដែលត្រូវបានអនុម័តដោយព្រឹទ្ធសភាកាលពីថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ ២០១៩។ ការស្នើធ្វើវិសោធនកម្មមានចំនួន១០មាត្រា រួមមាន មាត្រា៣ មាត្រា១៧ មាត្រា២០ មាត្រា២១ មាត្រា២៧ មាត្រា២៨ មាត្រា២៩ មាត្រា៥៤ មាត្រា៥៥ និងមាត្រា៥៩ ដោយមិនបានអនុលោមទៅតាមបទដ្ឋានការងារអន្តរជាតិផ្នែកការងារ និងត្រូវបានអនុម័តដោយគ្មានដំណើរការពិគ្រោះយោបល់ឲ្យល្អិតល្អន់ជាមួយភាគីពាក់ព័ន្ធ។

បទប្បញ្ញត្តិជាច្រើននៅក្នុងច្បាប់ស្តីពីសហជីពតម្រូវឲ្យមានការកែប្រែឡើងវិញ។ កិច្ចពិគ្រោះយោបល់ស្តីពីការធ្វើវិសោធនកម្មច្បាប់ស្តីពីសហជីពចុងក្រោយ នៅតែបន្តការរឹតត្បិតសិទ្ធិការងារ និងសិទ្ធិមនុស្ស តាមរយៈការកម្រិតសិទ្ធិសេរីភាពផ្នែកសមាគម សិទ្ធិក្នុងការចងក្រង និងសិទ្ធិក្នុងការចរចារជាសមូលហភាព។ យើងមានការកត់សម្គាល់ថាមានការធ្វើវិសោធនកម្មតិចតួចទៅលើច្បាប់នេះលើសំណេរដើមកន្លងមកដោយមិនទាន់គ្រប់គ្រាន់នៅឡើយ និងមិនត្រូវបានដោះស្រាយចំពោះបញ្ហាផ្សេងទៀត។ គណៈកម្មការជំនាញក្នុងការតាមដានត្រួតពិនិត្យ ការអនុវត្តន៍អនុសញ្ញា និងផ្តល់អនុសាសន៍ទៅលើសិទ្ធិសេរីភាពផ្នែកសមាគមរបស់អង្គការពលកម្មអន្តរជាតិផ្នែកការងារបានអំពាវនាវឲ្យមានការធ្វើវិសោធនកម្មជាច្រើនលើកទៅលើច្បាប់ស្តីពីសហជីពដែលមិនបានធ្វើការឆ្លុះបញ្ចាំងទៅលើមាត្រាដែលបានស្នើឡើង។ឧទាហរណ៍ រួមមានមាត្រា៣ មាត្រា១០ មាត្រា១២ មាត្រា១៣ មាត្រា២០ មាត្រា២១ មាត្រា២៨ មាត្រា៣៨ មាត្រា៥៩ និងការដាក់ពិន័យជំពូក១៥។

**ចំណុចព្រួយបារម្ភរបស់យើងខ្ញុំទៅលើសំណើរធ្វើវិសោធនកម្មច្បាប់ស្តីពីសហជីពរួមមាន៖**
១. ធ្វើវិសោធនកម្ម មាត្រា៣៖ មាត្រាបច្ចុប្បន្នមិនបានពង្រីកវិសាលភាពច្បាប់ស្តីពីសហជីពទៅដល់បុគ្គលដ៏ទៃទៀត ដែលត្រូវបានផ្តល់អនុសាសន៍ដោយការិយាល័យស្នងការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ។ មាត្រា៣ នៃច្បាប់ស្តីពីសហជីពបានចែងថា *ច្បាប់នេះគ្របដណ្តប់ទៅដល់បុគ្គលទាំងឡាយណាដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ* ចំណុចនេះរំលោភទៅលើមាត្រា៣៦ នៃច្បាប់រដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជាដែលធានាថា ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបង្កើតសហជីព និងចូលជាសមាជិកសហជីពនេះ។ ការស្នើធ្វើវិសោធនកម្មច្បាប់ស្តីពីសហជីពនៅទីនេះមិនបានគ្របដណ្តប់ឲ្យបានទូលំទូលាយទៅដល់កម្មករស្វ័យនិយោជន៍ គ្រូបង្រៀន និងមន្ត្រីរាជការសាធារណៈដ៏ទៃទៀត។ ទាក់ទងទៅនិងចំណុចនេះ កម្មករបម្រើការងារផ្ទះ និងសហគ្រាសតូចៗដែលមានកម្មករនិយោជិតតិចតួចក្រោម ១០នាក់ មិនមានចំនួនគ្រប់គ្រាន់ទៅតាមលក្ខខណ្ឌដែលច្បាប់កំណត់ថាចំនួនកម្មករនិយោជិត ១០នាក់ ទើបអាចបង្កើតសហជីពមូលដ្ឋាន ចំណុចនេះមានចែងនៅក្នុងមាត្រា១០ នៃច្បាប់ស្តីពីសហជីពដែលជាការបដិសេធទៅសិទ្ធិរបស់ពួកគេចូលរួមជាមួយសហជីព។

២. មាត្រា៥ (មិនបានផ្លាស់ប្តូរ)៖ មាត្រានេះនិយាយអំពី កម្មករនិយោជិត និងនយោជក មានសិទ្ធិបង្កើតសហជីព ឬសមាគមនិយោជក តាមការជ្រើសរើសរបស់ខ្លួន ក្នុងគោលបំណងសម្រាប់តែការសិក្សាស្រាវជ្រាវ បណ្តុះបណ្តាល ការលើកតម្កើងផលប្រយោជន៍ និងការការពារសិទ្ធិរបស់ខ្លួនតាមរយៈសហជីព។ ការិយាល័យស្នងការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិបានផ្តល់អនុសាសន៍ឲ្យដកចេញឃ្លា *"ក្នុងគោលបំណងសម្រាប់តែ"* ឃ្លានេះអាចរឹតត្បិតសិទ្ធិរបស់ស្ថាប័នក្នុងការសម្រេចចិត្តដោយសេរីទៅលើសកម្មភាពនិងកម្មវិធីការងាររបស់ពួកគេ។

៣. មាត្រា១២ (មិនបានផ្លាស់ប្តូរ)៖ មាត្រានេះនិយាយអំពីលក្ខខណ្ឌតម្រូវសម្រាប់ក្នុងការស្នើចុះបញ្ជីសហជីពត្រូវបានយល់ព្រម *ប្រសិនបើសំណើរសុំនោះបានបំពេញលក្ខខណ្ឌនោះគ្រប់គ្រាន់* រួមមាន លក្ខន្តិកៈ បទបញ្ជាផ្ទៃករដ្ឋបាលដែលគ្រប់គ្រងទៅលើការដឹកនាំ បញ្ជីរាយនាមថ្នាក់ដឹកនាំ កំណត់ត្រាសៀវភៅហិរញ្ញវត្ថុ កុងធានាគារ កំណត់ហេតុច្បាប់ដើមនៃការបោះឆ្នោតបង្កើតសហជីព។ មាត្រា១២ ដាក់លក្ខខណ្ឌខ្ពស់នៃការជ្រៀតជ្រែកសម្រេចដោយរដ្ឋាភិបាល និងកំណត់លក្ខខណ្ឌដាក់បន្ទុកទាមទារច្រើនសម្រាប់សហជីព។

៤. មាត្រា១៧ (មិនបានផ្លាស់ប្តូរ) មាត្រានេះរំលោភទៅលើសិទ្ធិក្នុងការសម្រេចចិត្តផ្ទៃក្នុងរបស់សហជីព។ ការធ្វើវិសោធនកម្មដាក់បន្ថែម យន្តការត្រួតពិនិត្យសាវនកម្មឯករាជ្យ ប្រសិនបើ ១០ភាគរយនៃចំនួនសមាជិកសហជីព ឬ ៥ ភាគរយនៃម្ចាស់ជំនួយស្នើឡើង។ យន្តការត្រួតពិនិត្យសាវនកម្មឯករាជ្យទាមទារឲ្យស្ថាប័នចុះបញ្ជីនៅក្នុងប្រទេសកម្ពុជាដែលអាចជាត់ចោលការប្រើប្រាស់ស្ថាប័នសាវនកម្មឯករាជ្យមានឈ្មោះល្អដែលបានចុះបញ្ជីនៅក្រៅប្រទេស។ ការធ្វើវិសោធនកម្មមិនបានបន្ថយ ឬធ្វើឲ្យមានភាពងាយស្រួលសម្រាប់តម្រូវការឯកសារដែលតម្រូវឲ្យសហជីពដាក់របាយការណ៍ទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ នៅពេលដែលមាត្រា ១៧ អានភ្ជាប់ជាមួយមាត្រា ១៨ ច្បាប់នេះមានប្រសិទ្ធិភាពផ្តល់អំណាចទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈធ្វើការលុបចោលបញ្ជិកាសហជីពប្រសិនបើសហជីពមិនបានបំពេញកាតព្វកិច្ចដែលបានកំណត់នៅក្នុងបទប្បញ្ញត្តិតាមរយៈលិខិតព្រមានពីរលើក។

៥. មាត្រា ១៨ (មិនបានផ្លាស់ប្តូរ) មាត្រានេះផ្តល់អំណាចទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈប្តឹងសហជីពទៅតុលាការដើម្បីរំលាយបញ្ជិកាសហជីព ប្រសិនបើសហជីពមិនបានបំពេញកាតព្វកិច្ចដែលបានកំណត់ដោយច្បាប់ស្តីពីសហជីព។ បើពិចារណាទៅលើទម្ងន់នៃឯកសារបែបបទរដ្ឋបាលទាមទារដោយច្បាប់ និងអ្នកអនុវត្តន៍ច្បាប់មានអំណាចកាន់តែលើសលុបក្នុងការធ្វើសេចក្តីសម្រេចថាតើលក្ខខណ្ឌតម្រូវទាំងនោះត្រូវបានបំពេញ ដោយសហជីពរបស់កម្មករប្រឈមហានិភ័យរំលាយដោយផ្អែកលើមូលដ្ឋានអំណាច និងការស្នើសុំដោយមិនមានហេតុផល។

៦.មាត្រា២០ មាត្រា២១ និងមាត្រា៣៨ បន្តដាក់បន្ទុកទៅលើសិទ្ធិសហជីពក្នុងការជ្រើសរើសអ្នកតំណាងក្នុងសិទ្ធិសេរីភាពពេញលេញ។

៧. មាត្រា៥៤(វិសោធនកម្ម) ការធ្វើវិសោធនកម្មមិនបានឲ្យច្បាប់នេះអនុលោមទៅតាមបទដ្ឋានអន្តរជាតិពីព្រោះមិនបានផ្តល់សិទ្ធិដល់ការចរចារជាសមូលហភាព និងការដោះស្រាយវិវាទរួមដល់សហជីពទាក់ទងទៅនឹងភាពជាតំណាងបំផុត។ នៅក្រោមច្បាប់ស្តីពីសហជីព សហជីពដែលមិនមានភាពជាតំណាងបំផុតបច្ចុប្បន្នត្រូវបានហាមឃាត់ពីការការពារផលប្រយោជន៍សមាជិករបស់ពួកគេ រួមទាំងត្រូវបានរារាំងពីការធ្វើជាតំណាងដោយអាណត្តិ ក្នុងការដោះស្រាយបណ្តឹងសារទុក្ខមុននីតិវិធីក្រុមប្រឹក្សាអជ្ញាកណ្តាល។

៨. នីតិវិធីស្នើសុំបញ្ជិកាសហជីព និងតម្រូវការលក្ខន្តិកៈសហជីព៖ តម្រូវការស្នើសុំបញ្ជិកាសហជីពមានភាពផ្ទុយគ្នាពីបទដ្ឋានអន្តរជាតិតាមរយៈការទាមទារការអនុញ្ញាតជាមុនដោយអាជ្ញាធរមានសមត្ថកិច្ច (រំលោភទៅលើមាត្រា២ នៃអនុសញ្ញាស្តួលលេខ៨៧ របស់អង្គការពលកម្មអន្តរជាតិផ្នែកការងារ) ការដាក់បន្ទុកទៅលើសិទ្ធិសហជីពក្នុងការតាក់តែងធម្មនុញ្ញ និងបទបញ្ជារបស់ខ្លួន (រំលោភទៅលើ មាត្រា៣ នៃអនុសញ្ញាស្តួលលេខ៨៧ របស់អង្គការពលកម្មអន្តរជាតិផ្នែកការងារ)។ ជាងនេះទៅទៀត ការកំណត់ចំពោះសហជីពដែលមានភាពជាតំណាងបំផុតគឺជាកម្មវត្ថុដើម្បីធ្វើការសម្រេចចិត្ត និងទទួលស្គាល់ដោយអាជ្ញាធរមានសមត្ថកិច្ចនៅពេលដែលឆន្ទានុសិទ្ធិនេះគួរកំណត់ដោយស្ថាប័នឯករាជ្យ។ ការធ្វើវិសោធនកម្មខកខានដើម្បីធានាឲ្យមានតម្លាភាព ប្រសិទ្ធិភាព និងដំណើរការងាយស្រួលក្នុងការស្នើសុំបញ្ជិកាសហជីពដែលធានាដល់សេរីភាពសមាគម សម្រាប់កម្មករនិយោជិត និងជាឧបសគ្គនៃការព្យួរបែបបទស្នើសុំបញ្ជិកាសហជីព។

៩. បច្ចុប្បន្នច្បាប់នេះមិនបានដាក់បញ្ចូលបទប្បញ្ញត្តិដើម្បីបង្កើនការការពារសម្រាប់កម្មករនិយោជិតដែលធ្វើការងារដោយប្រើប្រាស់កិច្ចសន្យាដែលមានថិរៈវេលាកំណត់ដើម្បីអនុវត្តន៍សិទ្ធិសេរីភាពខាងសមាគម។ មកទាល់ពេលនេះការរីករាលដាលនៃការប្រើប្រាស់កិច្ចសន្យាដែលមានថេរៈវេលាកំណត់បង្កើតឲ្យមានក្តីព្រួយបារម្ភចំណោមកម្មករនិយោជិតប្រសិនបើពួកគេចូលរួមជាមួយសហជីព អ្នកគ្រប់គ្រងនឹងមិនបន្តកិច្ចសន្យារបស់ពួកគេ។

យើងខ្ញុំទាំងគ្នាតំណាងឲ្យអង្គការសង្គមស៊ីវិលជាតិនិងអន្តរជាតិជំរុញសម្តេចនាយករដ្ឋមន្ត្រីធ្វើការពិចារណាទៅលើបទប្បញ្ញត្តិក្នុងច្បាប់ស្តីពីសហជីពទាំងអស់នេះឡើងវិញ និងពិចារណាដោយយកចិត្តទុកដាក់ចំពោះអនុសាសន៍ដែលបានផ្តល់ដោយការិយាល័យស្នងការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ និងអង្គការពលកម្មអន្តរជាតិផ្នែកការងារ។

តាមរយៈការធ្វើដូចនេះ រដ្ឋាភិបាលកម្ពុជាអាចធានាថាការកែប្រែបទប្បញ្ញត្តិនៃច្បាប់ស្តីពីសហជីពឡើងវិញបញ្ជាក់ពីកាតព្វកិច្ចរបស់ខ្លួនស្ថិតក្រោមកាតិការសញ្ញាស្តីពីសិទ្ធិមនុស្ស និងអនុសញ្ញាស្នូលអន្តរជាតិផ្នែកការងារនានា។

យើងទាំងអស់គ្នានិងធ្វេសប្រហែស ប្រសិនបើមិនបានលើកឡើងពីក្តីបារម្ភអំពីនីតិវិធីពិគ្រោះយោបល់ទៅលើច្បាប់ស្តីពីសហជីពនេះ។ កាលពីខែកក្កដា ឆ្នាំ២០១៩ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានចេញលិខិតអញ្ជើញចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ត្រីភាគី។ នៅក្នុងកិច្ចប្រជុំមានតំណាងសហជីពដែលគាំទ្ររាជរដ្ឋាភិបាល តំណាងរដ្ឋាភិបាល តំណាងនិយោជកចូលរួមច្រើនលើសលប់។ មានតំណាងសហជីពឯករាជ្យជាច្រើនមិនទទួលបានលិខិតអញ្ជើញឬត្រូវបានប្រាប់ថា ពួកគេត្រូវការលិខិតអញ្ជើញផ្ទាល់ពីក្រសួងការងារនិងបណ្តុំបណ្តាលវិជ្ជាជីវៈ។

តាំងពីមុននិងក្រោយការបោះឆ្នោតឆ្នាំ២០១៨ អ្នកតស៊ូមតិផ្នែកការងារ មេដឹកនាំសហជីព និងសកម្មជនសហជីពគឺជាមុខសញ្ញារបស់រាជរដ្ឋាភិបាល។ ខណៈពេលដែលយើងបានសម្គាល់ឃើញថា រាជរដ្ឋាភិបាលបានមានចំណាត់ការលើករណីចោទប្រកាន់ផ្នែកព្រហ្មទណ្ឌប្រឆាំងលើមេដឹកនាំសហព័ន្ធសហជីពមួយចំនួន ទទ្ទឹមនឹងនេះដែរ ករណីមួយចំនួនមិនអាចទទួលយកបាន ដូចជាករណី លោក គង់ អាទិត្យដែលបានរកឃើញថាមានទោសក្នុងករណីតវ៉ារបស់អ្នកបើកបរក្រុមហ៊ុនកាពីតូលកាលពីឆ្នាំ ២០១៦ ។ យើងទាំងអស់គ្នាមានការបារម្ភដោយមានការវិវត្តនតិចតួចចំពោះករណីទម្លាក់ចោលបទចោទប្រកាន់ទៅលើថ្នាក់ដឹកនាំនៅតាមសហជីពមូលដ្ឋាន។ លទ្ធផលនៃការបង្ក្រាបនេះត្រូវបានប្រើប្រាស់ដើម្បីធ្វើអោយស្ងប់ស្ងាត់មតិរិះគន់របស់សហជីពឯករាជ្យនិង ធ្វើឲ្យសាយភាយការភ័យខ្លាចក្នុងចំណោមសហជីពដែលហ៊ានក្រោកឈរទាមទារសិទ្ធិរបស់ពួកគេ។

បរិយាកាសនាពេលបច្ចុប្បន្នសម្រាប់អ្នកតស៊ូមតិផ្នែកការងារ មេដឹកនាំសហជីព សកម្មជនអង្គការសង្គមស៊ីវិលមិនទាន់បានដោះស្រាយដើម្បីធានាការធ្វើឲ្យប្រសើរឡើងដោយអាចជឿទុកចិត្តបានចំពោះស្ថានភាពសិទ្ធិមនុស្ស និងសិទ្ធិការងារនៅក្នុងប្រទេសកម្ពុជា។ យើងជម្រុញដល់រាជរដ្ឋាភិបាលឲ្យមានវិធានការជាជំហានបន្តបន្ទាប់ដូចខាងក្រោមៈ

១. ផ្តួចផ្តើមឲ្យមានការពិគ្រោះឡើងវិញប្រកបដោយតម្លាភាពទៅលើការធ្វើវិសោធនកម្មច្បាប់ស្តីពីសហជីពនៅខែមករា ឆ្នាំ២០២០ ដើម្បីធានាថាច្បាប់នេះត្រូវបានបានធ្វើវិសោធនកម្មអនុលោមពេញលេញទៅនឹងបទដ្ឋានអន្តរជាតិផ្នែកការងារ និងសិទ្ធិមនុស្ស។ កិច្ចពិគ្រោះយោបល់នេះគួរធ្វើឡើងដោយមានការចូលរួមពីការិយាល័យស្នងការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ អង្គការពលកម្មអន្តរជាតិផ្នែកការងារ អង្គការសង្គមស៊ីវិលជាតិនិងអន្តរជាតិ ជាពិសេសសហជីពឯករាជ្យ និងការដាក់លិខិតសម្រាប់ការអញ្ជើញចូលរួមគួរតែត្រូវបានចេញទុកមុន។ របាយការណ៍សរុប និងពង្រាងការធ្វើវិសោធនកម្មចុងក្រោយចេញពីកិច្ចពិគ្រោះ

យោបល់គួរត្រូវបានផ្សព្វផ្សាយជាសាធារណៈ និងចែករំលែកជាមួយរដ្ឋសភាជាតិ និងព្រឹទ្ធសភាដើម្បីជម្រាបពីការកែប្រែឡើងវិញទៅលើការធ្វើវិសោធនកម្មច្បាប់ស្តីពីសហជីព។

២. ទម្លាក់រាល់បទចោទប្រកាន់ប្រឆាំងលើមេដឹកនាំសហជីព កម្មករនិយោជិត និងសកម្មជនតស៊ូមតិលើសិទ្ធិការងារ។
៣. បញ្ឈប់រាល់ទម្រង់ការឃាយឃីទៅលើមេដឹកនាំសហជីព កម្មករនិយោជិត និងសកម្មជនតស៊ូមតិលើសិទ្ធិការងារ។

អរគុណសម្រាប់ការពិចារណារបស់ **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី។**

**ដោយក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ**

ចម្លងជូន

រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌